**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**លេខ** ..........០០១/១៣..........ក.ប/សណន

# សេចក្តីណែនាំ

## ស្តីពី

## ការបាញ់ថ្នាំសម្លាប់សត្វល្អិតនៅខាងក្នុង និងក្រៅបរិវេណ អគាររោងចក្រ សហគ្រាស គ្រឹះស្ថាន ក្រុមហ៊ុន

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ពិនិត្យឃើញថាក្នុងរយៈពេលថ្មីៗនេះមាននិយោជកមួយចំនួនបានបាញ់ថ្នាំសម្លាប់សត្វល្អិត ដើម្បីការពារសម្ភារៈ វត្ថុធាតុ ដើម ផលិតផល និងកសិករដែលមានស្រែចំការនៅជាប់ក្បែររបងរោងចក្រកាត់ដេរ និងផលិតស្បែកជើង បានបាញ់ថ្នាំសម្លាប់សត្វល្អិតនៅក្នុងស្រែដោយមិនបានអនុលោមតាមលក្ខខណ្ឌបច្ចេកទេស បង្កឱ្យមានការសាយភាយក្លិនជាតិគីមី ខណៈពេលដែលកម្មករនិយោជិតកំពុងធ្វើការ ជាមូលហេតុធ្វើឱ្យមានបញ្ហាកម្មករនិយោជិតសន្លប់ កើតឡើងជាបន្តបន្ទាប់ ។

ដើម្បីទប់ស្កាត់ និងបង្ការហានិភ័យលើបញ្ហានេះ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមណែនាំ ដូចខាងក្រោម៖

១/. ចំពោះការបាញ់ថ្នាំសម្លាប់សត្វល្អិតខាងក្នុងអគារផលិតកម្ម ឬឃ្លាំងស្តុកសម្ភារៈរោងចក្រ សហគ្រាស គ្រឹះស្ថាន ក្រុមហ៊ុនត្រូវ៖

- សហការជាមួយក្រុមហ៊ុនផ្តល់សេវាបាញ់ថ្នាំសត្វល្អិត ដើម្បីការពារកុំឱ្យមានក្លិនសាយភាយដល់កន្លែងការងារ (ទុករូបសំណាកថ្នាំគីមី, មានតារាងទិន្នន័យសុវត្ថិភាព និងកិច្ចសន្យាបាញ់ថ្នាំសត្វល្អិត...)
- បណ្តុះបណ្តាលបុគ្គលិកពីរបៀបប្រើប្រាស់សារធាតុថ្នាំសម្លាប់សត្វល្អិតឱ្យបានត្រឹមត្រូវ
- ការបាញ់ថ្នាំសម្លាប់សត្វល្អិតត្រូវជូនដំណឹងជាមុនដល់សហជីព ប្រតិភូបុគ្គលិក និងកម្មករនិយោជិត
- ធានាបានថាសារធាតុថ្នាំសម្លាប់សត្វល្អិតមិនសាយភាយដល់កន្លែងធ្វើការ។ ក្នុងករណីមានការសាយភាយក្លិន ត្រូវបើកប្រព័ន្ធបឺតខ្យល់ចេញក្រៅរហូតធានាបានថាមិនមានផលប៉ះពាល់ដល់សុខភាពកម្មករនិយោជិត
- មានច្រកសុវត្ថិភាពការងារចេញពីអគារផលិតកម្ម នៅពេលមានសញ្ញាប្រកាសអាសន្ន



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទៈ(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

- សញ្ញាការពារសុខភាព សុវត្ថិភាព ហើយត្រូវសរសេរជាអក្សរខ្មែរងាយអាន ងាយយល់ និងដាក់ឱ្យបានត្រឹមត្រូវតាមទីកន្លែងសមស្រប និងមានការថែរក្សាឱ្យនៅស្អាតជានិច្ច
- អនុវត្តឱ្យបានខ្ជាប់ខ្ជួនតាមប្រកាសលេខ ៣០៧ កប/ប្រក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៧ ស្តីពីលក្ខខណ្ឌ អនាម័យ និងសន្តិសុខការងារក្នុងរោងចក្រកាត់ដេរសំលៀកបំពាក់ និងដេរស្បែកជើង។

២/.ចំពោះការបាញ់ថ្នាំសម្លាប់សត្វល្អិតខាងក្រៅបរិវេណរោងចក្រ សហគ្រាស គ្រឹះស្ថាន ក្រុមហ៊ុន

- អាជ្ញាធរមានសមត្ថកិច្ចត្រូវជូនដំណឹងដល់ប្រជាកសិករដែលមានស្រែចំការនៅក្បែរអគាររោងចក្រ សហគ្រាស គ្រឹះស្ថាន ក្រុមហ៊ុន ឱ្យមានការជូនដំណឹងជាមុនដល់និយោជកម្ចាស់ សហគ្រាស គ្រឹះស្ថាន ក្រុមហ៊ុន ចំពោះការបាញ់ថ្នាំលើស្រែចំការរបស់ខ្លួន
- និយោជកត្រូវសហការណ៍ជាមួយនឹងអាជ្ញាធរដែនដី និងមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី/ខេត្ត ដើម្បីទទួលបានព័ត៌មានទាក់ទងនឹងការបាញ់ថ្នាំសត្វល្អិតដាក់ស្រែរបស់កសិករ ដោយធ្វើយ៉ាងណាកុំឱ្យប៉ះពាល់ដល់ថ្ងៃកម្មករនិយោជិតកំពុងធ្វើការ
- ករណីសារធាតុថ្នាំបាញ់សម្លាប់សត្វល្អិតដាក់ស្រែត្រូវបានភាយក្លិនមកចំទិសលំហូរខ្យល់បក់មកចំប្រព័ន្ធបឺតខ្យល់ចូលនៃអគារផលិតកម្ម និយោជកត្រូវបិទប្រព័ន្ធលំហូរខ្យល់ក្នុងអគារផលិតកម្ម និងផ្អាកផលិតកម្មភ្លាម។

៣/.ក្នុងករណីដែលមានឧបទ្ទវហេតុកើតឡើង ដោយការបាញ់ថ្នាំសម្លាប់សត្វល្អិត និយោជកត្រូវបើកប្រព័ន្ធខ្យល់ក្នុងអគារផលិតកម្មក្នុងរយៈពេល ២៤ម៉ោង គិតចាប់ពីថ្ងៃកើតហេតុរហូតដល់កម្មករនិយោជិតចូលធ្វើការវិញនៅថ្ងៃបន្ទាប់ ដើម្បីធានាបានថាស្ថានភាពក្លិនសារធាតុថ្នាំសម្លាប់សត្វល្អិតនេះត្រូវបានបឺតចេញអស់ និងគ្រប់ពេលកម្មករចូលធ្វើការរៀងរាល់ថ្ងៃត្រូវបើកប្រព័ន្ធខ្យល់ឱ្យបានមុន ៣០នាទី។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សង្ឃឹមយ៉ាងមុតមាំថា នាយក ម្ចាស់រោងចក្រ សហគ្រាស គ្រឹះស្ថាន ក្រុមហ៊ុន និងអាជ្ញាធរមានសមត្ថកិច្ចនានា នឹងចូលរួមអនុវត្តឱ្យបានល្អប្រសើរនូវ ខ្លឹមសារនៃសេចក្តីណែនាំនេះ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ មករា ឆ្នាំ២០១៦

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**